# ការសម្រេចបានឧត្តមភាព៖ ការវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធរបស់ចិនក្នុងតំបន់អាស៊ាន និងលើសពីនេះ

## ព្រឹត្តិប័ត្រព័ត៌មានទី៥៖ ធនាគារគោលនយោបាយរបស់ចិន

ធនាគារគោលនយោបាយរបស់ចិនបាន និងកំពុងប្រតិបត្តិការក្រៅប្រទេស អស់រយៈពេលជាងមួយទសវត្សរ៍រួចមកហើយ ដើម្បីគាំទ្រដល់យុទ្ធសាស្ត្រចេញក្រៅប្រទេស។ តាមរយៈយុទ្ធសាស្ត្រនេះ រដ្ឋចិនបានលើកកម្ពស់ក្រុមហ៊ុនចិនឲ្យពង្រីកនៅក្រៅប្រទេស ប្រើប្រាស់រូបិយវត្ថុអន្តរជាតិលើសតម្រូវការដើម្បីបង្កើនលទ្ធភាពចូលទៅក្នុងទីផ្សារអន្តរជាតិ ធនធានធម្មជាតិ និងបច្ចេកវិទ្យា។ ធនាគារគោលនយោបាយទាំងអស់នេះបានបង្កើតមូលនិធិ សម្រាប់ឲ្យប្រទេសចិនឈានឡើងយ៉ាងឆាប់រហ័សទៅជាអ្នកវិនិយោគទុនកំពូលរបស់ពិភពលោក។[1] ធនាគារទាំងនេះត្រូវបានបង្កើតឡើងនៅពាក់កណ្តាលទសវត្សរ៍ ១៩៩០ ដើម្បីបំបែកហិរញ្ញវត្ថុដែលមានទិសដៅបែបគោលនយោបាយចេញពីហិរញ្ញវត្ថុបែបពាណិជ្ជកម្ម។ មានធនាគារគោលនយោបាយចំនួនបីគឺ៖ ធនាគារអភិវឌ្ឍន៍ចិន (China Development Bank) ធនាគារ Eximbank ចិន និងធនាគារអភិវឌ្ឍន៍កសិកម្មនៃប្រទេសចិន (Agricultural Development Bank of China)។[2] ការបង្កើតធនាគារទាំងអស់នេះអនុញ្ញាតឲ្យធនាគារពាណិជ្ជកម្មរបស់រដ្ឋ "ធំៗទាំង៤" របស់ចិន (ធនាគារចិន ធនាគារសំណង់ចិន ធនាគារកសិកម្មប្រទេសចិន និងធនាគារឧស្សាហកម្ម និងពាណិជ្ជកម្មចិន) ផ្តោតការយកចិត្តទុកដាក់លើប្រតិបត្តិការពាណិជ្ជកម្ម។[3]

ធនាគារអភិវឌ្ឍន៍ចិន និងធនាគារនាំចេញនាំចូល (Eximbank) គឺជាអ្នកជម្រុញដ៏សំខាន់ចំពោះយុទ្ធសាស្ត្រចេញក្រៅប្រទេស ដោយបានវិនិយោគទឹកប្រាក់រាប់ពាន់លានដុល្លារនៅក្រៅប្រទេស។ ក្នុងនាមជាធនាគារគោលនយោបាយ តួនាទីរបស់ពួកគេគឺដើម្បីគាំទ្រផ្នែកគោលនយោបាយរបស់រដ្ឋាភិបាលចិន ហេតុនេះ ធនាគារទាំងពីរនឹងដើរតួនាទីដ៏សំខាន់ក្នុងការផ្តល់ហិរញ្ញវត្ថុសម្រាប់គម្រោងនានា ក្នុងការផ្តួចផ្តើមគំនិតខ្សែក្រវ៉ាត់មួយផ្លូវមួយ (សូមមើលព្រឹត្តិប័ត្រព័ត៌មានទី៣)។ ចាប់តាំងពីការប្រកាសសម្ពោធការផ្តួចផ្តើមគំនិតខ្សែក្រវ៉ាត់មួយផ្លូវមួយមក រដ្ឋាភិបាលចិនបានដាក់បញ្ចូលនូវដើមទុនដ៏ច្រើនទៅក្នុងធនាគារទាំងពីរ។ យោងតាមរបាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយបានឲ្យដឹងថា នៅចន្លោះខែមេសា ដល់ខែសីហា ឆ្នាំ២០១៥ ធនាគារកណ្តាលរបស់ចិនបានផ្តល់ដល់ធនាគារអភិវឌ្ឍន៍ចិននូវទឹកប្រាក់រូបិយវត្ថុអន្តរជាតិចំនួន ៩៤ ពាន់លានដុល្លារ និងធនាគារ Eximbank នូវទឹកប្រាក់ចំនួន ៩០ ពាន់លានដុល្លារដើម្បីគាំទ្រគម្រោងក្រៅប្រទេស។[4]

ធនាគារអភិវឌ្ឍន៍ចិនផ្តល់ហិរញ្ញវត្ថុពីរយៈពេលមធ្យមរហូតដល់រយៈពេលវែងចំពោះសកម្មភាព និងគម្រោងនានាដែលផ្សារភ្ជាប់ជាមួយយុទ្ធសាស្ត្រសេដ្ឋកិច្ចជាតិរបស់ចិន។ នៅក្នុងប្រទេសចិន សកម្មភាព និងគម្រោងទាំងអស់នេះ រួមមានទាំងគម្រោងហេដ្ឋារចនាសម្ព័ន្ធ ឧស្សាហកម្ម និងគម្រោងជាអាទិភាពជាតិដទៃទៀត។ យុទ្ធសាស្ត្រនេះក៏ផ្តល់ហិរញ្ញវត្ថុចំពោះការផ្តួចផ្តើមគំនិតផ្នែកការអប់រំ ការថែទាំសុខភាព កសិកម្ម ការសាងសង់ផ្ទះសម្រាប់អ្នកមានចំណូលទាប និងបរិស្ថានផងដែរ។[5] ធនាគារនេះដើរតួនាទីយ៉ាងធំធេងនៅក្នុង

ការវិនិយោគទុនក្រៅប្រទេសរបស់ចិន។ ក្នុងឆ្នាំ២០១៤ ធនាគារបានផ្តល់នូវកម្ចីរូបិយវត្ថុអន្តរជាតិក្នុងទឹកប្រាក់លើស ១០០ ពាន់លានដុល្លារអាមេរិក។[6] បើប្រៀបធៀបក្នុងឆ្នាំដដែលនេះ ក្រុមធនាគារពិភពលោកបានផ្តល់ប្រាក់កម្ចីចំនួន ៦១ ពាន់លានដុល្លារអាមេរិក។[7]

ចំណែកនៅក្នុងប្រទេសវិញ ធនាគារអភិវឌ្ឍន៍ចិនបានគាំទ្រគដល់គម្រោងខ្នាតធំដូចជាទំនប់ Three Gorges គម្រោងផ្ទេរទឹកខាងត្បូង-ខាងជើង និងបណ្តាញថាមពលអគ្គិសនី ផ្លូវ និងគម្រោងផ្លូវដែកល្បឿនលឿនជាច្រើនថែមទៀត។ នៅតំបន់អាស៊ាន ធនាគារបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រុមប្រឹក្សាភិបាលវិនិយោគរបស់ប្រទេសថៃ ដើម្បីលើកកម្ពស់ការវិនិយោគទុនទ្វេភាគី ហើយបានផ្តល់ហិរញ្ញប្បទានសម្រាប់បំពង់បង្ហូរឧស្ម័នចិន-ភូមាដែលមានភាពចម្រូងចម្រាសគ្នាយ៉ាងខ្លាំង រោងចក្រថាមពលធ្យូងថ្ម Vung Ang ក្នុងប្រទេសវៀតណាម និងទំនប់វារីអគ្គិសនីស្ទឹងអាតៃក្នុងប្រទេសកម្ពុជា ព្រមទាំងគម្រោងផ្សេងៗជាច្រើនទៀត។ ធនាគារក៏បានផ្តល់អាហារូបករណ៍ដល់សិស្សមកពីប្រទេសឡាវឲ្យទៅសិក្សាក្នុងប្រទេសចិនផងដែរ។

ស្របពេលដែលធនាគារបន្តអភិវឌ្ឍអាជីវកម្មអន្តរជាតិរបស់ខ្លួន ការផ្តួចផ្តើមគំនិតខ្សែក្រវ៉ាត់មួយផ្លូវមួយនឹងក្លាយទៅជាការផ្តោតការយកចិត្តទុកដាក់ជាយុទ្ធសាស្ត្រ។[8] ធនាគារបានផ្តល់ ៥% នៃដើមទុនដំបូងរបស់មូលនិធិផ្លូវសូត្រ ហើយក៏មានមូលនិធិជាក់លាក់សម្រាប់ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ានផងដែរ។ ឧទាហរណ៍ ក្នុងឆ្នាំ២០១៤ នាយករដ្ឋមន្ត្រីចិន Li Keqiang បានសន្យាផ្តល់ប្រាក់ ២០ ពាន់លានដុល្លារអាមេរិក ដើម្បីគាំទ្រការតភ្ជាប់រវាងប្រទេសចិនជាមួយអាស៊ីអាគ្នេយ៍ ដែលក្នុងនោះរួមមានទាំងកម្ចីពិសេសក្នុងទឹកប្រាក់ ១០ ពាន់លានដុល្លា បង្កើតឡើងដោយធនាគារអភិវឌ្ឍន៍ចិនសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់។[9]

## បទដ្ឋានបរិស្ថាន និងសង្គមរបស់ធនាគារអភិវឌ្ឍន៍ចិន

ធនាគារអភិវឌ្ឍន៍ចិនអះអាងថាខ្លួនមានបទដ្ឋានសម្រាប់គ្រប់គ្រងលើផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម បង្កឡើងដោយសកម្មភាពរបស់ខ្លួន។ ទោះយ៉ាងណាក្តី ធនាគារបានបោះពុម្ពផ្សាយតែអត្ថបទសង្ខេបរបស់ខ្លួនប៉ុណ្ណោះ ចំណែកឯកសារទាំងស្រុងពុំបានដាក់ជូនជាសាធារណៈទេ។ព័ត៌មានតែមួយគត់ដែលមានស្តីអំពីគោលនយោបាយទាំងនេះ គឺមាននៅក្នុងរបាយការណ៍របស់ធនាគារមកពីឆ្នាំថ្មីៗនេះប៉ុណ្ណោះ។ យោងតាមឯកសារសង្ខេបទាំងអស់នេះបានឲ្យដឹងថា ការវាយតម្លៃលើគម្រោងដែលត្រូវបានស្នើឡើង រួមមានការវាយតម្លៃលើហានិភ័យផ្នែកបរិស្ថាន និងសង្គម។ ការដាក់ពាក្យស្នើសុំប្រាក់កម្ចីចាំបាច់ត្រូវដាក់បញ្ចូលនូវការវាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថាន ហើយធនាគារអាចបដិសេធការស្នើសុំបានដោយឈរលើមូលដ្ឋានផ្នែកបរិស្ថាន។ ជាពិសេស ធនាគារអាចសរសេរបទដ្ឋានផ្នែកបរិស្ថាន ហើយគិតប្រាក់បញ្ចូលទៅក្នុងកិច្ចព្រមព្រៀងប្រាក់កម្ចី ដើម្បីដាក់កាតព្វកិច្ចឱ្យអ្នកខ្ចីប្រាក់អនុវត្តការប្តេជ្ញាចិត្តផ្នែកបរិស្ថានរបស់ខ្លួន។[10] ធនាគារអភិវឌ្ឍន៍ចិនក៏ជាសមាជិកមួយរបស់សន្ធិសញ្ញាសកលអង្គការសហប្រជាជាតិ និងការផ្តួចផ្តើមគំនិតហិរញ្ញវត្ថុកម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិផងដែរ។ ធនាគារនេះនៅមិនទាន់បានចុះហត្ថលេខាលើគោលការណ៍អេក្វាទ័រនៅឡើយទេ ប៉ុន្តែបានបង្កើតក្រុមការងារផ្ទៃក្នុងសម្រាប់គោលការណ៍អេក្វាទ័រ ហើយអះអាងថាគោលការណ៍ទាំងនេះត្រូវបានអនុវត្តជាបណ្តើរៗ នៅក្នុងការអភិវឌ្ឍអាជីវកម្មរបស់ខ្លួន។[11]

ស្របពេលដែលធនាគារបានធ្វើការប្តេជ្ញាចិត្តជាច្រើន ហើយមានបទដ្ឋានផ្ទៃក្នុងសម្រាប់គ្រប់គ្រងហានិភ័យផ្នែកបរិស្ថាន និងសង្គមក្តី ប៉ុន្តែដំណើរវាយតម្លៃនៅពុំទាន់ប្រកបដោយតម្លាភាពនៅឡើយ។ ធនាគារពុំបានបោះពុម្ពផ្សាយឯកសារណាមួយស្តីពីគម្រោងជាក់លាក់ ហើយពុំមានយន្តការបណ្តឹងសាទុក្ខ ឬបណ្តាញប្រាស្រ័យទាក់ទងផ្លូវការសម្រាប់ប្រជាជនរងផលប៉ះពាល់នោះឡើយ។ គេហទំព័ររបស់ធនាគារពុំផ្តល់នូវបញ្ជីឈ្មោះគ្រប់ជ្រុងជ្រោយអំពីគម្រោងទាំងនោះឡើយ។ ការពុំមានតម្លាភាពទាំងនេះដាក់ដែនកំណត់យ៉ាងធំធេងលើប្រសិទ្ធភាពនៃគោលនយោបាយផ្នែកសង្គម និងបរិស្ថានដែលធនាគារអាចមាននាពេលបច្ចុប្បន្ន។

中国进出口银行
THE EXPORT-IMPORT BANK OF CHINA

ធនាគារ Eximbank ចិន ត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់ និងសម្របសម្រួលដល់ការនាំចេញ និងនាំចូលផលិតផលចិន ជួយសម្រួលដល់ក្រុមហ៊ុនចិនក្នុងគម្រោងក្រៅឆ្នេរសមុទ្រដើម្បីចុះកិច្ចសន្យា និងការវិនិយោគក្រៅប្រទេស ព្រមទាំងលើកកម្ពស់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិ។[12] ដូចគ្នានឹងធនាគារអភិវឌ្ឍន៍ចិនដែរ ធនាគារ Eximbank គឺជាអ្នកគាំទ្រដ៏ធំមួយចំពោះក្រុមហ៊ុនចិនដែលចេញទៅក្រៅប្រទេស ហើយចូលរួមនៅក្នុងគម្រោងនៅទូទាំងពិភពលោក។ ក្នុងឆ្នាំ២០១៤ ធនាគារបានបញ្ចេញទឹកប្រាក់ចំនួន ៩២១ ពាន់លាន RBM (ស្មើនឹង ១៤២ ពាន់លានដុល្លារអាមេរិក) ក្នុងប្រាក់កម្ចី។[13] ការឲ្យខ្ចីទាំងនេះ ភាគច្រើនផ្តោតការយកចិត្តទុកដាក់លើហេដ្ឋារចនាសម្ព័ន្ធ ឧស្សាហកម្ម និងពាណិជ្ជកម្ម ដោយក្នុងនោះរួមមានទាំងការបញ្ជូនទំនិញ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ប្រេងឥន្ធនៈ និងឧស្ម័ន ថាមពលទូរគមនាគមន៍ ផលិតកម្ម និងគម្រោងកសិកម្ម។ កម្ចីភាគច្រើនរបស់ធនាគារ Eximbank គឺជាកម្ចីបែបពាណិជ្ជកម្ម ប៉ុន្តែធនាគារក៏ទទួលខុសត្រូវចំពោះការឱ្យខ្ចីបែបសម្បទានរបស់ចិនផងដែរ។ កម្ចីសម្បទានសំដៅលើកម្ចី និងឥណទានទាំងឡាយដែលមានអត្រាការប្រាក់ទាបជាងទីផ្សារ និងរយៈពេលសងវិញយូរ។ ភាគច្រើននៃជំនួយក្រៅប្រទេសរបស់ចិនគឺធ្វើតាមរយៈប្រាក់កម្ចីទាំងនេះ។[14]

ការគាំទ្រដល់ការតភ្ជាប់នៅក្នុងបណ្តាប្រទេសជិតខាង គឺជាការផ្តោតការយកចិត្តទុកដាក់ចម្បងរបស់ធនាគារ Eximbank។ ធនាគារបានថ្លែងថាខ្លួន "ព្យាយាមសម្រេចបានការអភិវឌ្ឍអាជីវកម្មដោយគោរពតាមយុទ្ធសាស្ត្រការទូតថ្មីរបស់ចិន" ដោយក្នុងនោះរួមមានទាំងយុទ្ធសាស្ត្រខ្សែក្រវ៉ាត់មួយផ្លូវមួយផងដែរ។[15] ធនាគារនេះគឺជាអ្នកដើរតួផ្នែកហិរញ្ញវត្ថុដ៏សំខាន់មួយនៅក្នុងអាស៊ាន ដោយធនាគារបានផ្តល់ការផ្គត់ផ្គង់ហិរញ្ញវត្ថុដល់គម្រោងនានា រួមទាំង គម្រោងទំនប់វារីអគ្គិសនីកំចាយក្នុងប្រទេសកម្ពុជា គម្រោងផ្លូវហាយវ៉េ Bac Giang-Lang Son និងរោងចក្រផលិតថាមពលធ្យូងថ្ម Vin Than ក្នុងប្រទេសវៀតណាម ទំនប់ និងប្រព័ន្ធបញ្ជូនថាមពលជាច្រើនក្នុងប្រទេសឡាវ មីក្រូហិរញ្ញវត្ថុក្នុងប្រទេសមីយ៉ាន់ម៉ា និងការអភិវឌ្ឍលំនៅដ្ឋានរយៈពេលយូរក្នុងក្រុងបាងកកប្រទេសថៃ។ ធនាគារ Eximbank គឺជាអ្នកផ្តល់មូលនិធិកំពូល និងជាអ្នកគ្រប់គ្រងលើមូលនិធិសហប្រតិបត្តិការវិនិយោគចិន-អាស៊ាន (សូមមើលព្រឹត្តិប័ត្រព័ត៌មានទី៤)។ ធនាគារនេះក៏ចូលរួមយ៉ាងច្រើននៅក្នុងការវិនិយោគផ្លូវដែកថ្នាក់តំបន់របស់ចិនផងដែរ។ នៅចុងឆ្នាំ២០១៥ ធនាគារបាន

ចុះហត្ថលេខាលើកិច្ចព្រមព្រៀងកម្ចីមួយជាមួយសហប្រតិបត្តិការផ្លូវដែករបស់រដ្ឋចិន ដើម្បីគាំទ្រដល់ការពង្រីកទៅក្រៅប្រទេសរបស់ខ្លួន។ កិច្ចព្រមព្រៀងនេះរួមបញ្ចូលនូវបន្ទាត់ឥណទានក្នុងទឹកប្រាក់រហូតដល់ ៥០០ ពាន់លានយ័ន (ជិតស្មើ ៨០ ពាន់លានដុល្លាអាមេរិក)។ សាជីវកម្មផ្លូវដែកចិនចូលរួមនៅក្នុងគម្រោងអភិវឌ្ឍន៍ផ្លូវដែកដែលត្រូវបានស្នើឡើងក្នុងប្រទេសឥណ្ឌូនេស៊ី ឡាវ និងថៃ ដែលគម្រោងទាំងអស់នេះអាចទទួលបានកម្ចីពីធនាគារ Eximbank តាមរយៈកិច្ចព្រមព្រៀងនេះ។[16]

## បទដ្ឋានផ្នែកបរិស្ថាន និងសង្គមរបស់ធនាគារ Eximbank

ធនាគារ Eximbank បានធ្វើលើសពីស្ថាប័នហិរញ្ញវត្ថុចិនភាគច្រើន ក្នុងការបើកបង្ហាញអំពីបទដ្ឋាន និងគោលនយោបាយផ្នែកសង្គម និងបរិស្ថានរបស់ខ្លួន។ ធនាគារនេះមានគោលនយោបាយជាមូលដ្ឋានមានឈ្មោះថា*គោលការណ៍ណែនាំសម្រាប់ការវាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គមរបស់គម្រោងកម្ចីនៃធនាគារនាំចេញ និងនាំចូលរបស់ចិន។* គោលការណ៍ណែនាំនេះទាក់ទងជាមួយគម្រោងទាំងក្នុងស្រុក និងក្រៅស្រុក ហើយគ្របដណ្តប់លើការវាយតម្លៃគម្រោង ការវាយតម្លៃផ្នែកបរិស្ថាន ការគ្រប់គ្រង និងមើលខុសត្រូវលើកម្ចី។ គោលការណ៍ណែនាំបញ្ជាក់ថា អ្នកខ្ចីចាំបាច់ត្រូវតែគោរពតាមច្បាប់ និងបទបញ្ជាផ្នែកបរិស្ថានក្នុងស្រុកនៅពេលធ្វើការវិនិយោគក្រៅប្រទេស។ ក្នុងករណីដែលប្រព័ន្ធ និងបទបញ្ជាក្នុងស្រុកមានភាពមិនគ្រប់គ្រាន់នោះអ្នកខ្ចីត្រូវបានបញ្ជាឲ្យអនុវត្តបទដ្ឋានរបស់ចិន ឬ "ការអនុវត្តជាអន្តរជាតិ"។[17]

គោលការណ៍ណែនាំរបស់ធនាគារ Eximbank ក៏បានបញ្ជាក់ដោយសង្ខេបអំពីសិទ្ធិដីធ្លី និងសិទ្ធិលើធនធាន ព្រមទាំងបញ្ជាក់ថា ការតាំងទីលំនៅថ្មីត្រូវតែដោះស្រាយឲ្យសមស្រប ហើយគម្រោងដែលមានផលប៉ះពាល់ធ្ងន់ធ្ងរគួរបើកឲ្យមានការពិគ្រោះយោបល់ជាសាធារណៈ។ ធនាគារ Eximbank មានអំណាចក្នុងការចុះត្រួតពិនិត្យគម្រោងក្នុងអំឡុងពេលអនុវត្ត ហើយប្រសិនបើមានការលេចឡើងនូវហេតុប៉ះពាល់ធ្ងន់ធ្ងរក្នុងអំឡុងការអភិវឌ្ឍ ឬប្រតិបត្តិការគម្រោង ធនាគារអាចបញ្ឈប់ការបញ្ចេញប្រាក់កម្ចី ហើយទាមទារឲ្យសងមកវិញមុនការកំណត់ ប្រសិនបើអ្នកខ្ចីពុំបានចាត់វិធានការសមស្របដើម្បីដោះស្រាយបញ្ហានោះទេ។[18] ធនាគារ Eximbank ក៏អាចស្នើសុំឲ្យអតិថិជននោះកែតម្រូវអាកប្បកិរិយា បង្កកឥណទានមិនទាន់ប្រើប្រាស់ ចេញការព្រមាន អនុវត្តការដាក់កំហិតលើអាជីវកម្ម និងដកឥណទានមកវិញ ប្រសិនបើអ្នកខ្ចីពុំអនុវត្តតាម។[19]

ថ្វីបើគោលការណ៍ណែនាំផ្នែកបរិស្ថាន និងសង្គម ឆ្នាំ២០០៧ មានចែងយ៉ាងជាក់ច្បាស់លើគម្រោងក្រៅប្រទេស ហើយនិយាយពាក់ព័ន្ធជាមួយបញ្ហាជាគន្លឹះមួយចំនួនទៀតក្តី ប៉ុន្តែឯកសារនេះមានលក្ខណៈជាឯកសារមូលដ្ឋាន ហើយមានតែអត្ថបទខ្លីៗចំនួន ២១ ប៉ុណ្ណោះ។ ពុំមានច្រកផ្លូវការណាមួយដែលសាធារណៈជនអាចស្នើសុំព័ត៌មានស្តីពីគម្រោងជាក់លាក់ ហើយក៏ពុំមានយន្តការបណ្តឹងសារទុក្ខផ្លូវការដែរ។ ការវាយតម្លៃគម្រោងពុំមានលក្ខណៈបើកចំហរ ហើយធនាគារពុំមានផ្សព្វផ្សាយអំពីឯកសារគម្រោងឡើយ។ ដូចគ្នានឹងករណីរបស់ធនាគារចិនដែរ ប្រសិទ្ធភាពរបស់គោលការណ៍ណែនាំមានភាពថមថយគួរឱ្យកត់សម្គាល់ដោយសារតែចំណុចខ្វះខាតទាំងនេះ ប៉ុន្តែទោះយ៉ាងណាគោលការណ៍ណែនាំទាំងនេះនៅតែជាឯកសារយោងក៏មានសារៈប្រយោជន៍សម្រាប់សហគមន៍ និងក្រុមសង្គមស៊ីវិលដែលព្យាយាមចូលរួមជាមួយធនាគារ ឬចង់ធ្វើការស្វែងរកការគាំទ្រជុំវិញគម្រោង ដែលផ្តល់មូលនិធិដោយធនាគារ Eximbank។

*ព្រឹត្តិប័ត្រព័ត៌មាននេះដកស្រង់ចេញពីរបាយការណ៍អង្គការ Inclusive Development International ដែលមានចំណងជើងថា [Making Inroads: Chinese Infrastructure Investment in ASEAN and Beyond](#) ។*

*ការស្រាវជ្រាវ និងការអភិវឌ្ឍឯកសារបោះពុម្ពផ្សាយនេះបានទទួលការគាំទ្រពី Heinrich-Böll-Stiftung South East Asia, The McKnight Foundation and Planet Wheeler Foundation*

*ការបោះពុម្ពផ្សាយនេះបានទទួលអាជ្ញាប័ណ្ណអនុញ្ញាតក្រោម Creative Commons Attribution-Non Commercial-ShareAlike 4.0 International License* (cc) BY-NC-SA

---

[1] Kynge, J. (2016, 18 May), *China becomes global leader in development finance*, Financial Times. http://www.ft.com/intl/cms/s/3/b995cc7a-1c33-11e6-a7bc-ee846770ec15.html (accessed May 2016).

[2] Research Academy of China Development Bank (2011), *China Development Bank Practice and Achievements of Development Finance,* Beijing: Democracy and Construction Press.

[3] Erica Downs (2011), *Inside China, Inc.: China Development Bank's Cross-Border Energy Deals*, Washington DC: Brookings Institution, p.12.

[4] Zhang, Y. (2015, 21 July), *Policy Banks Linked to 'Belt and Road' Plans Said to Get US$ 31 Bln*, Caixin Online. http://english.caixin.com/2015-07-21/100831133.html (accessed May 2016); Xinhua (2015, 18 August), *China raises capital base of development bank*, Xinhuanet. http://europe.chinadaily.com.cn/business/2015-08/18/content_21640335.htm (accessed May 2016).

[5] China Development Bank (2015), *Annual Report 2014*, Beijing: CDB.

[6] *Ibid*., p.12.

[7] World Bank (2014, 1 July), *World Bank Group Commitments Rise Sharply in FY14 Amid Organizational Change*. http://www.worldbank.org/en/news/press-release/2014/07/01/world-bank-group-commitments-rise-sharply-in-fy14-amid-organizational-change (accessed May 2016).

[8] *Ibid*., p.17.

[9] Xinhua (2014, 13 September), *China pledges over 20-bln-USD loans to boost Southeast Asian connectivity*, Xinhuanet.http://news.xinhuanet.com/english/china/2014-11/13/c_133787970.htm (accessed May 2016).

[10] Matisoff, A. (2012), *China Development Bank's Overseas Investments: An assessment of environmental and social policies and practices*, Berkeley: Friends of the Earth. http://www.foe.org/news/archives/2012-07-new-report-on-china-development-bank-shows-the-bank.

[11] China Development Bank (2013, 7 August), *Tightening EIA to Promote Multilateral Win-Win Outcome – CDB's "Green Credit" Goes to the World*. http://www.cdb.com.cn/english/NewsInfo.asp?NewsId=4715 (accessed May 2016).

[12] Export-Import Bank of China, *Brief Introduction*. http://english.eximbank.gov.cn/tm/en-TCN/index_617.html (accessed May 2016).

[13] Export-Import Bank of China (2014), *Annual Report 2014*, Beijing: China Eximbank.

[14] Grimsditch, M. & Yu, Y. (2015),*Development Finance in the BRICS Countries: A Review from China*, New Delhi: Heinrich Böll Foundation. https://za.boell.org/sites/default/files/development_finance_in_brics_countries.pdf (accessed May 2016).

[15] Export-Import Bank of China (2014), *Annual Report 2014*, Beijing: China Eximbank.

[16] Xinhua (2015, 19 November), *China Exim Bank to finance China Railway's global projects*, Xinhuanet.http://news.xinhuanet.com/english/2015-11/19/c_134834239.htm (accessed May 2016).

[17] Export-Import Bank of China (2008), *Guidelines for Environmental and Social Impact Assessments of the China Export and Import Bank's Loan Projects*.

[18] *Ibid.*

[19] Friends of the Earth US (2016), *Emerging Sustainability Frameworks: China Development Bank and China Export-Import Bank*, Washington DC: FOE. http://www.foe.org/projects/economics-for-the-earth/international-finance/emerging-sustainability-frameworks.